MentalHigh
Building Mental Health Capacity at Higher Education Institutes in Southeast Asia

Co-funded by the Erasmus+ Programme of the European Union

# MentalHigh Newsletter volume 1

គម្រោង MentalHigh- កសាងសមត្ថភាពសុខភាពផ្លូវចិត្តនៅតាមបណ្ដាគ្រឹះស្ថានឧត្តមសិក្សា (HEIs) ក្នុងតំបន់អាស៊ីអាគ្នេយ៍–គម្រោងនេះមានរយៈពេល 3 ឆ្នាំដែលសហការឧបត្ថម្ភដោយកម្មវិធី Erasmus+ របស់សហភាពអឺរ៉ុប (Erasmus+ International Capacity Building Project 101082744) ចាប់ពីខែឧសភា ឆ្នាំ 2023 ដល់ខែមេសា ឆ្នាំ 2026 ។ Project Coordinator: HAW Hamburg, Prof. Dr. Gunter Groen។

គោលបំណងរបស់គម្រោង MentalHigh របស់យើងគឺចង់កសាងសមត្ថភាពសុខភាពផ្លូវចិត្តនៅក្នុងគ្រឹះស្ថានឧត្តមសិក្សាក្នុងប្រទេសកម្ពុជានិងវៀតណាម ជាមួយនឹងគោលដៅរយៈពេលវែង ដើម្បីប្រែក្លាយសាកលវិទ្យាល័យទៅជាទីកន្លែងគាំទ្រដល់សុខភាព ដែលអាចធ្វើឱ្យនិស្សិត និងបុគ្គលិកទាំងអស់អភិវឌ្ឍខ្លួន ហើយទទួលបានជោគជ័យតាមសក្ដានុពលល្អបំផុតរបស់ពួកគេ។

គម្រោង MentalHigh អនុវត្តតាមគោលការណ៍ Setting-based approach (គោលការណ៍ដោះស្រាយ និងលើកកម្ពស់បញ្ហាសុខភាពផ្អែកលើបរិបទ និងមជ្ឈដ្ឋាន) ដោយធ្វើការជជែកពិភាក្សាជាមួយអ្នកធ្វើការសម្រេចចិត្ត បុគ្គលិកសិក្សា អ្នកផ្ដល់សេវា និងនិស្សិត តាមរយៈការផ្សាភ្ជាប់ការអន្តរាគមន៍បង្ការ និងការលើកកម្ពស់សុខភាពផ្លូវចិត្តតាមរបៀបជាច្រើនផ្សេងៗគ្នា។

លទ្ធផលចម្បងរបស់គម្រោង MentalHigh គឺជាទម្រង់ឌីជីថលសុខភាពផ្លូវចិត្ត ដែលផ្ដល់ឱ្យនិស្សិតនូវភាពងាយស្រួលក្នុងការប្រើប្រាស់ធនធានសុខភាពផ្លូវចិត្ត និងជាប្រពៃណីនៃការគាំទ្រសុខភាពផ្លូវចិត្ត ទាំងនៅក្នុងនិងក្រៅបរិវេណសាកលវិទ្យាល័យ។

## សមិទ្ធកម្មការសម្រេចបានរបស់គម្រោង MentalHigh ក្នុងរយៈពេល ៦ខែដំបូង



# MentalHigh Newsletter volume 1



*ថ្ងៃទី 19 ខែកញ្ញា ឆ្នាំ 2024 ក្នុងបរិវេណសាកលវិទ្យាល័យអប់រំ VNU ទីក្រុងហាណូយ ប្រទេសវៀតណាម*

## កិច្ចប្រជុំក្នុងការងារដំបូងក្នុងទីក្រុងហាណូយ

គម្រោង MentalHigh បានចាប់ផ្តើមដំណើរការរបស់ខ្លួនជាមួយនឹងកិច្ចប្រជុំ ដែលមានរយៈពេល 3 ថ្ងៃ គឺចាប់ពីថ្ងៃទី 19 ដល់ថ្ងៃទី 21 ខែកញ្ញា ឆ្នាំ 2023 នៅសាកលវិទ្យាល័យអប់រំ VNU ក្នុងទីក្រុងហាណូយ។ កិច្ចប្រជុំនេះគឺជាពេលវេលាដ៏មានសារៈសំខាន់សម្រាប់ពួកយើង ក្នុងការនាំមកនូវការជួបជុំគ្រប់ដៃគូសហការទាំងអស់របស់គម្រោង MentalHigh ពីប្រាំប្រទេសខុសៗគ្នា ដើម្បីកសាងនូវមូលដ្ឋានគ្រឹះនៃកិច្ចខិតខំប្រឹងប្រែងសហការរួមគ្នាឈានទៅរកសុខភាពផ្លូវចិត្តរបស់និស្សិតសាកលវិទ្យាល័យ នៅអាស៊ីអាគ្នេយ៍។

លោក Jesús Laviña អនុប្រធានកិច្ចសហប្រតិបត្តិការ - គណៈប្រតិភូនៃសហភាពអឺរ៉ុប ប្រចាំទីក្រុងហាណូយ បានធ្វើការស្វាគមន៍ទៅដល់គ្រប់ស្ថាប័នដៃគូទាំងអស់របស់គម្រោង MentalHigh ក្នុងទីក្រុងហាណូយ។ លោកបានលើកសសើរពីការសម្រេចបាននៃក្រុមការងារ MentalHigh ក្នុងការដោះស្រាយបញ្ហាបន្ទាន់មួយក្នុងបញ្ហាសុខភាពផ្លូវចិត្តជាសកល និងបានធ្វើការសន្យាថា នឹងផ្តល់ការគាំទ្រដើម្បីឈានទៅដល់គោលដៅនៃកែលម្អសុខភាពផ្លូវចិត្តរបស់និស្សិត នៅគ្រឹះស្ថានឧត្តមសិក្សានៅប្រទេសវៀតណាម និងកម្ពុជា។ កិច្ចប្រជុំនេះផ្តោតទៅលើការពិភាក្សាស៊ីជម្រៅ ការរៀបចំផែនការយុទ្ធសាស្ត្រ និងការពិនិត្យមើលទៅលើការយល់លក្ខណៈលម្អិតនៃគោលបំណង និងទស្សនៈរបស់គម្រោង។ អាកាសធាតុដ៏កក់ក្តៅនៃទីក្រុងហាណូយ ហាក់ដូចជាឆ្លុះបញ្ចាំងឱ្យយើងឃើញពីភាពរីករាយ និងសុទិដ្ឋនិយម ពីព្រោះយើងសម្រេចបាននូវការកសាងគ្រឹះដ៏រឹងមាំសម្រាប់ជោគជ័យ គម្រោងរបស់យើង។

បន្ទាប់ពីកិច្ចប្រជុំ ការបរិភោគអាហារពេលល្ងាចជុំគ្នាប្រកដោយបរិយាកាសស្និទ្ធស្នាលបានប្រព្រឹត្តទៅផងដែរ។ យើងមានអារម្មណ៍វិជ្ជមាន និងការសហការគ្នាយ៉ាងល្អក្នុងចំណោមក្រុមការងារ ហើយយើងពិតជាអរគុណទៅដល់ពេលវេលាដ៏ល្អ និងទំនាក់ទំនងដែលយើងបានបង្កើតឡើង។ ពេលវេលាទាំងនេះ មិនត្រឹមតែបានបង្កើតនូវកិច្ចប្រជុំមួយដែលពោពេញដោយបរិយាកាសរីករាយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរៀបចំឱ្យយើងនូវគ្រឹះនៃការងាររួមគ្នាប្រកបដោយប្រសិទ្ធភាពក្នុងពេលអនាគត់ផងដែរ។

Co-funded by the Erasmus+ Programme of the European Union



## ក្រុមប្រឹក្សាភិបាលពីខាងក្រៅ និងក្រុមប្រឹក្សាភិបាលនិស្សិត

នៅខែតុលា ឆ្នាំ 2023 ក្រុមការងារនៃគម្រោង MentalHigh បានសម្រេចបាននូវការជ្រើសរើស ក្រុមប្រឹក្សាភិបាលពីខាងក្រៅ គម្រោងរបស់យើង។ ក្រុមប្រឹក្សាភិបាល នឹងជួយយើងត្រួតពិនិត្យទៅលើការរីកចម្រើននៃគម្រោង វាយតម្លៃថាតើសកម្មភាពណាមួយបានសម្រេចតាមលទ្ធផលរំពឹងទុក និងផ្តល់យោបល់ទៅលើការសម្រេចចិត្តលក្ខណៈយុទ្ធសាស្រ្តប្រចាំឆ្នាំ។ ជំនាញ និងការយល់ដឹងដ៏ស៊ីជម្រៅរបស់ក្រុមប្រឹក្សាភិបាលពីខាងក្រៅ នឹងពិតជារួមចំណែកដល់ការសម្រេចបាន នូវគោលដៅគម្រោងរបស់យើង និងធានាបាននូវគុណភាពនៃការងាររបស់យើង។ ក្នុងតារាងខាងស្តាំដៃ អ្នកនឹងឃើញបញ្ជីសមាជិកក្រុមប្រឹក្សាភិបាលរបស់យើង។

| | | |
|---|---|---|
|  | **RUPP** | Father. Kevin Conroy |
| | **NIE** | Dr. Soeng Sopha |
|  | **VNU Ued** | Nguyễn Quý Thanh |
| | **HCM USSH** | Nguyen Thi Thuy Dung |
| | **TUAF** | Duong Van Thao |
| | **TUEBA** | Nguyễn Thị Thu Thương |
| | **VUTED** | Thai Anh Tuan |
|  | **HAW Hamburg** | Prof. Dr. rer. nat. Wolf Polenz |
|  | **TUAS** | Camilla Laaksonen |

| | | |
|---|---|---|
|  | **VNU Ued** | Dương T.H. |
| | | Phan T.D. |
| | **HCM USSH** | Pham K.H. |
| | | Doan K.H |
| | **TUAF** | Ho C.B. |
| | | Nguyen T.V. |
| | **TUEBA** | Phạm M.T. |
| | | Trương T.T. |
| | **VUTED** | Vi B.Q |
| | | Phan T.H. |
|  | **RUPP** | Hoeurn Y. |
| | | Kim K. |
| | **NIE** | Phall M. |
| | | Thai S. |

ក្រុមប្រឹក្សាភិបាលបន្តទៅទៀតនេះ៖ គឺសមាជិកក្រុមប្រឹក្សាភិបាលនិស្សិត (SB) ក្រុមនិស្សិតត្រូវបានជ្រើសរើសចេញពី សាកលវិទ្យាល័យវៀតណាមចំនួន 5 និងកម្ពុជាចំនួន 2។ នៅថ្ងៃទី 8 ខែមករា ឆ្នាំ 2024 និស្សិតសរុបចំនួន 14 នាក់បានស្ម័គ្រចិត្តក្លាយជាក្រុមប្រឹក្សានិស្សិតក្នុងគម្រោង MentalHigh និងបានចូលរួមក្នុងកិច្ចប្រជុំស្វាគមន៍។ ក្រុមប្រឹក្សាភិបាលនិស្សិត (SB) ដែលនឹងបំពេញបន្ថែមក្នុងការអនុវត្តគម្រោង និងដើរតួនាទីជាអ្នកភ្ជាប់ទំនាក់ទំនងទៅកាន់ក្រុមគោលដៅ។ ឈ្មោះរបស់សមាជិកក្រុមប្រឹក្សានិស្សិត មានក្នុងតារាងដែលស្ថិតនៅខាងឆ្វេងដៃ តំណាងដោយត្រកូលរបស់ពួកគេនិងអក្សរកាត់ជាឈ្មោះ ដើម្បីរក្សានូវឯកជនភាពរបស់ពួកគេ។

Co-funded by the
Erasmus+ Programme
of the European Union

# MentalHigh Newsletter volume 1

## ដៃគូគម្រោង

- Hamburg University of Applied Sciences (Project coordinator)
- VNU University of Education, Vietnam
- Turku University of Applied Sciences, Finland
- Universitat Jaume I, Spain
- VNUHCM University of Social Sciences and Humanities, Vietnam
- Thai Nguyen University of Agriculture and Forestry, Vietnam
- Thai Nguyen University of Economics and Business Administration, Vietnam
- Vinh University of Technology Education, Vietnam
- Royal University of Phnom Penh, Cambodia
- National Institute of Education, Cambodia

## Contact Details

For further information or media inquiries, please contact: https://mentalhigh.net/